ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៩១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ ..

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលរបស់រាជរដ្ឋាភិបាលកម្ពុជា។

មាត្រា២ ..

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលមានប្រភពហិរញ្ញប្បទាន ដូចខាងក្រោម៖

- គម្រោងហិរញ្ញប្បទានដោយថវិកាជាតិ
- គម្រោងហិរញ្ញប្បទានក្រៅប្រទេស
- គម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- គម្រោងវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានចម្រុះ
- គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ
- គម្រោងវិនិយោគសាធារណៈ ដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត
- គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម
- គម្រោងវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត។

ជំពូកទី២
សមត្ថកិច្ចក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

មាត្រា៣ ..

ក្រសួងផែនការមានសមត្ថកិច្ចដឹកនាំ សម្របសម្រួល និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន។

ជំពូកទី៣
នីតិវិធីនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

មាត្រា៤ ..

កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ត្រូវបានរៀបចំនិងកែលម្អជារៀងរាល់ឆ្នាំ ដែលដឹកនាំ សម្របសម្រួល និងរៀបចំដោយក្រសួងផែនការនិងមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន។

មាត្រា៥ ..

គម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលសម្រាប់វិស័យរបស់ក្រសួងស្ថាប័ន ត្រូវបានរៀបចំឡើងដើម្បីសម្រេចបានអាទិភាពជាតិនិងវិស័យតាមខ្លឹមសារ និងស្មារតីនៃការជូនដំណឹងស្តីពីការរៀបចំព័ត៌មានគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលចេញដោយក្រសួងផែនការ។

មាត្រា៦ ..

ការពិនិត្យ វាយតម្លៃ កំណត់អាទិភាពរបស់គម្រោងទាំងអស់និងការចងក្រងសេចក្តីព្រាងកម្មវិធី វិនិយោគសាធារណៈ ត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យតាមចំណាត់ថ្នាក់អាទិភាពរបស់គម្រោងនីមួយៗពីគ្រប់ក្រសួង ស្ថាប័ន ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ។

មាត្រា៧ ..

ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលត្រូវផ្អែកលើមូលដ្ឋាននៃអាទិភាពជាតិដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងការសម្របសម្រួលរវាងគោលដៅនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលជាមួយនឹងកម្មវិធីអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍនិងលទ្ធភាពស្រូបយកហិរញ្ញប្បទានពីប្រភពផ្សេងៗរបស់កម្ពុជាសម្រាប់រៀបចំគម្រោងវិនិយោគសាធារណៈ៣ឆ្នាំ រំកិលរបស់ក្រសួង ស្ថាប័ននីមួយៗ។

CamScanner

មាត្រា៨ ..

ក្រសួងផែនការ ត្រូវរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងលក្ខណៈវិនិច្ឆ័យដែលត្រូវប្រើក្នុងការកំណត់អាទិភាពគម្រោង ពិន្ទុ និងមេគុណ ដែលត្រូវផ្តល់ក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ ពិន្ទុមធ្យមសរុបរបស់គម្រោងនីមួយៗ ចំណាត់ថ្នាក់អាទិភាពតាមពិន្ទុមធ្យមសរុបរបស់គម្រោងនីមួយៗ។

មាត្រា៩ ..

ក្រសួងផែនការ ត្រូវជូនដំណឹងដល់បណ្តាក្រសួង ស្ថាប័ន ដើម្បីរៀបចំកម្មវិធីវិនិយោគសាធារណៈសម្រាប់វិស័យរបស់ខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់។

មាត្រា១០ ..

ក្រសួងស្ថាប័ន ត្រូវរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុងឆ្នាំកន្លងមកនិងដោយមានការចូលរួមពីក្រុមការងារថវិកា ហើយផ្ញើជូនទៅក្រសួងផែនការដោយមានការចុះហត្ថលេខាបញ្ជាក់របស់រដ្ឋមន្ត្រី សាមីក្រសួងឬប្រធានស្ថាប័ន។

មាត្រា១១ ..

ក្រសួងផែនការ ត្រូវយកគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលរៀបចំដោយក្រសួង ស្ថាប័ន ចងក្រងជាសេចក្តីព្រាង និងរៀបចំបញ្ជីសង្ខេបស្តីពីគម្រោងកំពុងដំណើរការ បេក្ខភាពគម្រោងដែលមានប្រភពហិរញ្ញប្បទានសន្យាផ្តល់និងបេក្ខភាពគម្រោងដែលស្វែងរកប្រភពហិរញ្ញប្បទាន។

មាត្រា១២ ..

ក្រសួងផែនការ ត្រូវដឹកនាំរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងដើម្បីពិនិត្យរួមគ្នាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល រួចផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្ទៀងផ្ទាត់បញ្ជីគម្រោងមុននឹងដាក់ស្នើសេចក្តីព្រាងនេះទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច។

មាត្រា១៣ ..

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យនិងសម្រេចមុនការអនុម័តលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។

មាត្រា១៤ ..

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលបានទទួលការសម្រេចពីគណៈរដ្ឋមន្ត្រីសម្រាប់ជាធាតុចូលដើម្បីរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមក្របខ័ណ្ឌថវិការយៈពេលមធ្យម និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា១៥ ..

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់គម្រោងដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលនិងគម្រោងផ្សេងៗទៀត ដែលទទួលបានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ជាមូលដ្ឋានក្នុងការពិនិត្យវាយតម្លៃ ជ្រើសរើស និងធ្វើថវិកានីយកម្ម។

មាត្រា១៦ ..

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវយកកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលគណៈរដ្ឋមន្ត្រីបានសម្រេចទៅធ្វើការអំពាវនាវ កៀរគរកជំនួយមកគាំទ្រដល់ការអនុវត្តរាល់គម្រោងវិនិយោគសាធារណៈដែលមិនទាន់មានទុនអនុវត្តនិងផ្តល់ព័ត៌មានអំពីលទ្ធផលនៃការកៀរគរកជំនួយមកគាំទ្រដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ។

CamScanner

មាត្រា១៧ ..

ក្រសួង ស្ថាប័នត្រូវអនុវត្តឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពនូវកម្មវិធីវិនិយោគសាធារណៈ ដែលគណៈរដ្ឋមន្ត្រីបានសម្រេច។

ជំពូកទី៤
ប្រតិទិនរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

មាត្រា១៨ ..

ក្នុងខែវិច្ឆិកា ក្រសួងផែនការ ត្រូវជូនដំណឹងដើម្បីណែនាំបណ្តាក្រសួង ស្ថាប័នឱ្យរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យរបស់ខ្លួន។

មាត្រា១៩ ..

ក្នុងខែមករា បណ្តាក្រសួង ស្ថាប័នត្រូវផ្ញើគម្រោងកម្មវិធីវិនិយោគសាធារណៈទាំងអស់ក្នុងវិស័យរបស់ខ្លួនទៅក្រសួងផែនការ។

មាត្រា២០ ..

ក្នុងខែមករានិងខែកុម្ភៈ ក្រសួងផែនការត្រូវពិនិត្យវាយតំលៃគម្រោងដែលផ្តល់ដោយក្រសួង ស្ថាប័នចងក្រង សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងពិភាក្សាលើបញ្ជីគម្រោងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនពេលដាក់ឆ្លងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង។

មាត្រា២១ ..

ក្នុងខែកុម្ភៈ ក្រសួងផែនការ ត្រូវរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងដើម្បីពិនិត្យរួមគ្នាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល រួចផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យផ្ទៀងផ្ទាត់បញ្ជីគម្រោងនិងបញ្ជូនសេចក្តីព្រាងដែលបានកែសម្រួលរួចជូនគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច។

មាត្រា២២ ..

ក្នុងខែមីនា គណៈរដ្ឋមន្ត្រីធ្វើការពិនិត្យនិងសម្រេចលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

មាត្រា២៣ ..

ក្នុងខែមេសា បន្ទាប់ពីទទួលបានការសម្រេចពីគណៈរដ្ឋមន្ត្រី ក្រសួងផែនការត្រូវបន្តនីតិវិធីក្នុងការបោះពុម្ពនិងផ្សព្វផ្សាយឯកសារកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលនេះ។

ជំពូកទី៥
ការវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

មាត្រា២៤ ..

ក្រសួង ស្ថាប័នទាំងអស់ ត្រូវមានក្រុមការងារវាយតម្លៃសមិទ្ធកម្មប្រចាំក្រសួង ស្ថាប័នរបស់ខ្លួនដើម្បីធ្វើការពិនិត្យនិងវាយតម្លៃលទ្ធផលនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យរបស់ខ្លួន។

មាត្រា២៥ ..

ក្រសួង ស្ថាប័នទាំងអស់ដែលជាម្ចាស់គម្រោងវិនិយោគសាធារណៈត្រូវរៀបចំរបាយការណ៍សមិទ្ធកម្មតាមរបបរបាយការណ៍ នៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុងវិស័យរបស់ខ្លួនត្រូវជូនក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

មាត្រា២៦ ..

ក្រសួង ស្ថាប័នទាំងអស់ដែលជាម្ចាស់គម្រោងវិនិយោគសាធារណៈ ត្រូវបង្កលក្ខណៈងាយស្រួលឱ្យក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុងវិស័យរបស់ខ្លួន។

CamScanner

មាត្រា២៧ ..

ក្រសួងផែនការត្រូវវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលទៅលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការកែលម្អ ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

មាត្រា២៨ ..

ក្នុងករណីចាំបាច់ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមីត្រូវសហការពិគ្រោះយោបល់ ដើម្បីស្នើកែតម្រូវកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

ជំពូកទី៦
ប្រភពធនធាន

មាត្រា២៩ ..

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការផ្តល់ថវិកាសម្រាប់គាំទ្រដល់ដំណើរការនៃការរៀបចំនិងវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

ក្រសួង ស្ថាប័នមានសិទ្ធិទទួល ប្រើប្រាស់ និងចាត់ចែងតាមនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នូវប្រភពធនធានដែលបានមកពីដៃគូអភិវឌ្ឍនិងពីប្រភពស្របច្បាប់ផ្សេងៗ សម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា៣០ ..

អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣១ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

CamScanner